# ខ្លឹមសារ សង្ខេប

## ស្ដីពី ចំណុចប្រៀបធៀបរវាង កំមុនឡ និង ស៊ីវិលឡ

Joseph Dainow, Civil Law and the Common Law: Some Points of Comparison, 15 (3) the American Journal of Comparative Law (1966-67), pp. 419-435

១. **<u>ស៊ីវិលឡ (Civil Law):</u>** ជាពាក្យ ឡាតាំង *jus civile* ប្រើសម្រាប់ជនជាតិ រ៉ូម៉ាំង។ នេះខុសពី *Jus Gentium* ដែលជាច្បាប់ប្រើសម្រាប់មនុស្សទូទៅ។ *jus civile* ជាវិធាន ប្រើសម្រាប់ទំនាក់ទំនងរវាងបុគ្គល ដូចជាកិច្ចសន្យា កាតព្វកិច្ចបុគ្គលជាដើម។ ស៊ីវិលឡ កើតជាយូរយា មុនកំមុនឡ។ ប្រព័ន្ធនេះ ផ្ដោតលើ ច្បាប់ដែលត្រូវបានបង្កើតតាមនីតិវិធីផ្លូវការ ដោយសភា។ ក្រោយការបង្កើត មានការចង (codification) ដោយស្ដេច Justinian (ស្ដេច រ៉ូម៉ាំង)។ យោបល់របស់អ្នកច្បាប់ ជួយបំភ្លឺបញ្ហា មានការផ្ដល់តម្លៃជាខ្លាំង។ ដូចនេះហើយ កាលបើនិយាយពីទ្រឹស្ដីច្បាប់ ខាងប្រព័ន្ធស៊ីវិលឡ ឈានមុខដើរមុនជាងប្រព័ន្ធកំមុនឡ។ វិធានទាំងនោះ ត្រូវបានចងក្រងជាក្រម។ ច្បាប់រ៉ូម៉ាំង បានសាយភាយដល់ទឹកដីមួយចំនួន នៃទ្វីបអ៊ឺរ៉ុប។

ដោយសារផ្អែកលើច្បាប់ ការបកស្រាយក្នុងទំនាក់ទំនងបុគ្គល មានលក្ខណៈទូលាយ និងពិនិត្យមើលជាសំខាន់ចេតនារបស់អ្នកធ្វើច្បាប់។ ច្បាប់ត្រូវគេផ្ដល់តម្លៃទីមួយ និងចម្បង មុនប្រភពផ្សេងៗទៀតនៃច្បាប់។ ប្រព័ន្ធនេះ មិនប្រើយុត្តិសាស្ត្រទេ (precedent) តែទោះបីជាយ៉ាងនេះក្ដី តុលាការប្រទេសខ្លះ នឹងប្រើនៅពេលច្បាប់មិនមានចែង ឬចែងមិនច្បាស់។ ជាក់ស្ដែង ប្រទេសខ្លះ ប្រកាន់យក *juris prudence constante* ជាចំណុចច្បាប់ជាក់លាក់ ដែលអនុម័តក្នុងសេចក្ដីសម្រេចជាច្រើន មានសង្គតភាពគ្នា។ ការយោងនេះ ដើម្បីសំអាងគាំទ្រ សេចក្ដីសម្រេចរបស់ខ្លួន។

ក្នុងប្រព័ន្ធស៊ីវិលឡ ចៅក្រម ព្រះរាជអាជ្ញា មេធាវី ត្រូវមានចំណេះដឹងច្បាប់ជាមូលដ្ឋាន និងទទួលការបណ្ដុះបណ្ដាលដោយឡែកផ្សេងគ្នា។ ដើម្បីឆ្លងចូលវិជ្ជាជីវៈថ្មី ដូចជាមេធាវី ចង់ក្លាយជាចៅក្រម វាតម្រូវឲ្យមានការប្រឡង។ ការបណ្ដុះបណ្ដាលផ្ដោតលើច្បាប់ ទ្រឹស្ដី ក្នុងលក្ខណៈអរូបិយ។ ទោះបីជាយ៉ាងនេះក្ដី ការបង្រៀនច្បាប់ ក្នុងប្រទេសខ្លះ ក៏មានការប្រើករណីសិក្សាផងដែរ (*travaux pratiques*)។ ចំពោះបញ្ហាការស្រាវជ្រាវ ជាបឋម គេពិនិត្យមើលច្បាប់ បទអត្ថាធិប្បាយច្បាប់ និងក្ដីកាំ។

ក្នុងការសម្រេចសេចក្តី ចៅក្រម ចាប់ផ្តើមពីគោលការណ៍ទូទៅ មុនចូលទៅករណីជាក់លាក់។ ប្រសិនបើ ច្បាប់មានភាពជាក់លាក់ហើយ នឹងសម្រេចតាមច្បាប់ ទោះបីជាយ៉ាងនេះក្តី ចៅក្រម មានឆន្ទានុសិទ្ធិទូលាយ។ ក្នុងដំណើរការក្តី ជាទូទៅ មិនមាន Jury (អង្គប្រឹក្សាយោបល់ដល់តុលាការ) ដូចកំមុនឡទេ។ ចៅក្រម ក្នុងពេលសវនាការ គ្រប់គ្រងគ្រប់ដំណាក់កាលនៃសវនាការ។ ចៅក្រមសម្រេចរួមដោយអនាមិក និងមិនមានទម្លាប់ បញ្ចេញទស្សនៈយល់ឃើញ ឬជំទាស់ទេ (dissenting opinion)។ តុលាការកាន់តែខ្ពស់ សេចក្តីសម្រេចកាន់តែខ្លី។ ពេលមានបណ្តឹង ចៅក្រមត្រូវតែទទួលមកពិនិត្យ មិនអាចបដិសេធទេ ពីព្រោះអាចនឹងមានទោសពីបទបដិសេធយុត្តិធម៌ (denial of justice)។ ករណីគ្មានច្បាប់ជួយ ក្រមរដ្ឋប្បវេណី នៃប្រទេសស្វីស ចែងថា *ចៅក្រម ត្រូវសម្រេច ហាក់ដូចខ្លួនជាអ្នកធ្វើច្បាប់* (legislator)។ ប្រទេសបារាំង និង បែលស៊ិក ចៅក្រមត្រូវបានណែនាំឲ្យធ្វើសេចក្តីសម្រេច។ មាត្រា ២១ នៃក្រមរដ្ឋប្បវេណីរបស់ប្រទេស Lousiana ចែងថា *ចៅក្រមត្រូវសម្រេចដោយសមធម៌ តាមច្បាប់ធម្មជាតិ ករណីគ្មានច្បាប់ចែង*។ ចៅក្រមអាឡឺម៉ង់ នឹងបំពេញ ចន្លោះនៃច្បាប់ តាមការប្រើច្បាប់ទំនៀមទម្លាប់។ ករណី ការបង្កើតច្បាប់ដោយចៅក្រម គឺជាករណីពិសេស ដោយសារ ចៅក្រមទាំងនោះ ត្រូវពិចារណាជាចម្បងច្បាប់សរសេរ ដោយសារជាប្រភពចម្បង។ ចៅក្រមអាចបង្កើតវិធានច្បាប់ថ្មីបាន តាមការផ្ទេរអំណាចធ្វើច្បាប់ជាពិសេស ឬ ក្នុងករណីជាច្រើន តាមអំណាចបកស្រាយនៃអត្ថបទច្បាប់។[1]

**<u>២. កំមុនឡ (common law):</u>** ប្រព័ន្ធច្បាប់នេះ កើតក្រោយ ស៊ីវិលឡ ដោយផ្តើមពីការសម្រេចក្តីរបស់ តំបន់នីមួយៗ។ ក្រោយមក ស្តេច បានបង្កើតនូវតុលាការ ហើយវិធាន ដែលតុលាការបង្កើតកាន់តែមានភាពរឹងមាំខ្លាំង។ នៅពេលមិនមានច្បាប់ ឬវិធាន (របស់ចៅក្រម) ហើយជាបញ្ហាចម្បង ស្តេចបង្កើតតុលាការដោះស្រាយ ដោយប្រើ ទ្រឹស្តីសមធម៌ (equity)។ តុលាការបង្កើតវិធានរួម ដែលក្លាយជាកំមុនឡ។ សភា ត្រូវបានបង្កើតក្រោយមក ហើយតុលាការបានព្យាយាមរក្សាតម្លៃ កំមុនឡរបស់ខ្លួនដោយកុំឲ្យប៉ះពាល់ដោយច្បាប់សភា តាមរយៈការបកស្រាយតឹងរឹងនៃច្បាប់សភា។ តុលាការ ប្រើយុត្តិសាស្ត្រ (precedent) សម្រាប់អង្គហេតុដូចគ្នា។ ក្នុងករណីនេះ ចៅក្រមមិនចាំបាច់ពិចារណា ឬសរសេរសាលក្រមវែងទេ។ ចៅក្រម ក៏អាចមិនតាម និងបដិសេធយុត្តិសាស្ត្របានផងដែរ។[2]

[1] When a civil judge establishes new rules of law, he does so either by virtue of an exceptional legislative delegation or in most instances by virtue of his power of interpretation of the legislative text.

[2] Need publication of judgment.

ប្រព័ន្ធនេះ ក៏ងាកមកធ្វើច្បាប់ ដើម្បីឲ្យកាន់តែមានភាពជាក់លាក់ និងបំពេញបន្ថែម។ ក៏ប៉ុន្តែ ចៅក្រម មិនដាក់ច្បាប់ជាប្រភពចំបងទេនាពេលសម្រេចសេចក្ដី។ ពាក់ព័ន្ធនឹងការបង្កើតទ្រឹស្ដីច្បាប់ មិនសូវមានផុសផលតាមរយៈការស្រាវជ្រាវទេ តែតាមរយៈយុត្តិសាស្ត្រ។ អាស្រ័យហេតុនេះ ខុសពីស៊ីវិលឡ កាលណានិយាយពីបុគ្គលល្បីល្បាញក្នុងវិស័យច្បាប់ គេសំដៅលើចៅក្រមសម្រេចសេចក្ដី។ ពាក់ព័ន្ធនឹងការអប់រំ អ្នកប្រកបវិជ្ជាជីវៈច្បាប់ អាចឆ្លងអាជីពគ្នា តាមការជ្រើសរើស។ ការបណ្ដុះបណ្ដាល ប្រើប្រាស់សេចក្ដីសម្រេច ឬសាលក្រមជាចម្បងមកពិចារណា។

ការសម្រេចសេចក្ដី មាន Jury ហើយចៅក្រមម្នាក់ៗ អាចបញ្ចេញយោបល់ផ្ទាល់ខ្លួនបាន។ ចៅក្រមដំបូងពិនិត្យមើល អង្គហេតុទាំងអស់ កំណត់បញ្ហា និងយុត្តិសាស្ត្រ ដែលមានដើម្បីប្រើប្រាស់។ សេចក្ដីសម្រេច ត្រូវបានធ្វើការកត់ត្រា នឹងផ្សព្វផ្សាយជាសាធារណៈ។ ករណីច្បាប់មិនមាន ឬគ្មានយុត្តិសាស្ត្រ ចៅក្រម អាចបង្កើតវិធានបាន។

បណ្ឌិត មាស បូរ៉ា សណ្ឋាគារ Bao Son International Hotel, HaNoi, Viet Nam, 8 September 2019